# បដិមាព្រះអធ៌នារីស្វរមកពីតំបន់កោះកេរ

ក្នុងអំឡុងសង្គ្រាមស៊ីវិល (ទសវត្សរ៍១៩៧០-១៩៩០) វត្ថុបុរាណខ្មែរជាច្រើនសន្ធឹកសន្ធាប់ ត្រូវបានជនទុច្ចរិតលួចយកចេញ និងចរាចរលក់ដូរដោយខុសច្បាប់ទៅក្រៅប្រទេស។ ទោះបីជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាសេនាធិការ បានសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ ក្នុងការទាមទារត្រឡប់មកវិញនូវវត្ថុបុរាណខ្មែរទាំងនោះមកកាន់ប្រទេសកម្ពុជាវិញ។ ជាក់ស្តែង នៅខែកក្កដា ឆ្នាំ២០២៤ វត្ថុបុរាណខ្មែរចំនួន ៧០ ដុំ បានវិលត្រឡប់មកកាន់កម្ពុជាវិញ ដែលក្នុងចំណោមនោះមានបដិមាសំខាន់ៗចំនួន ៣៣ ដុំ ត្រូវបានប្រគល់មកវិញដោយគ្រួសារ Lindemann នៃសហរដ្ឋអាមេរិក។ វត្ថុបុរាណទាំងនោះភាគច្រើនមានប្រភពមកពីតំបន់ប្រាសាទកោះកេរ ដែលជាអតីតរាជធានីខ្មែរនៅស.វ.ទី១០។ គួរឱ្យចាប់អារម្មណ៍ ក្នុងចំណោមវត្ថុបុរាណទាំងនោះ មានបដិមាព្រះអធ៌នារីស្វរចំនួន ១ អង្គ ដែលមានប្រភពដើមមកពីប្រាសាទក្រចាប់ នៃតំបន់កោះកេរ ដែលជនទុច្ចរិតលួចយកចេញកាលពីទសវត្សរ៍១៩៩០។ តើអ្វីទៅជាព្រះអធ៌នារីស្វរ? តើបដិមាព្រះអធ៌នារីស្វរមកពីតំបន់កោះកេរនេះមានលក្ខណៈដូចម្តេច?

ព្រះអធ៌នារីស្វរ គឺសំដៅដល់ទិដ្ឋភាពមួយនៃព្រះឥសូរដែលមានព្រះកាយមួយចំហៀងខ្លួនជាស្រី ដែលតំណាងឱ្យការរួមបញ្ចូលគ្នារវាងបុរសនិងស្ត្រី គឺព្រះឥសូរនៅខាងស្តាំ និងព្រះជាយារបស់ទ្រង់ដែលមានព្រះនាមថា "**បវ៌តី**" នៅខាងស្តាំ។ ការរួមបញ្ចូលគ្នានេះ ជានិម្មិតរូបបង្ហាញអំពីភោគផល និងការរក្សាតុល្យភាពនៃលោកតាមរយៈភាពផ្ទុយគ្នានៃភេទ។ យោងទៅតាមគម្ពីរសិវបុរាណបានរៀបរាប់ថា *"ព្រះព្រហ្មដែលជាអ្នកបង្កើតលោក បានបង្កើតតែបុរសតែប៉ុណ្ណោះ តែមិនអាចបង្កើតសត្វលោកឱ្យបេះបន្តពូជបាន។ ម្ល៉ោះហើយ ព្រះព្រហ្មបានទៅសុំពរពីព្រះឥសូរឱ្យជួយដោះស្រាយផលវិបាកនេះ។ ពេលនោះ ព្រះឥសូរក៏បង្ហាញព្រះកាយរបស់ទ្រង់ជាព្រះអធ៌នារីស្វរ ដែលមានលក្ខណៈប្រុសនិងស្រីរួមបញ្ចូលគ្នា ដើម្បីបង្ហាញដល់ព្រះព្រហ្មថា ដើម្បីអាចបង្កើតអ្វីៗគ្រប់យ៉ាងបាន គឺមិនអាចខ្វះ "**សក្តិ**" ដែលជាថាមពលភេទស្រីបានឡើយ។ បន្ទាប់ពីឃើញដូច្នេះហើយ ព្រះព្រហ្មក៏បង្កើតមនុស្សស្រីឡើង"*។ រីឯគម្ពីរស្កន្ទបុរាណរៀបរាប់ថា *"ព្រះនាងបវ៌តីមានភក្តីភាពយ៉ាងជ្រាលជ្រៅចំពោះព្រះឥសូរ ហើយប្រាថ្នាចង់ឱ្យព្រះនាងនិងព្រះ*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

*ឥស្វរលែងបែកបាក់គ្នាទៀត និងចង់បានភាពពេញលេញជាមួយព្រះស្វាមីរបស់ទ្រង់។ ព្រះនាងបានធ្វើតបយ៉ាងតឹងរ៉ឹងបំផុត ដើម្បីបួងសួងឱ្យសេចក្តីប្រាថ្នារបស់ព្រះនាងបានសម្រេច។ ក្រោយមក ដោយមានព្រះហឫទ័យរំជួលចិត្តនឹងកក្តីភាពរបស់ព្រះនាង ព្រះឥស្វរក៏បានយល់ព្រមតាមសេចក្តីប្រាថ្នារបស់ព្រះនាង ដោយបានរួមបញ្ចូលព្រះកាយព្រះនាងបវ៌តីឱ្យក្លាយទៅជាចំណែកមួយនៃព្រះអង្គកាយរបស់ទ្រង់នៅផ្នែកខាងឆ្វេង ទើបពេលនោះហើយដែលទ្រង់បានក្លាយទៅជាព្រះអធ៌នារីស្វរ។*

បដិមាព្រះអធ៌នារីស្វរដែលទើបទាមទារត្រឡប់មកកម្ពុជានេះ សាងឡើងអំពីថ្មភក់ឈរនៅលើទម្រមួយរាងបួនជ្រុងស្មើ ដែលកម្ពស់បដិមាមានប្រវែង១៧៣ស.ម. និងកម្រាស់២៨ស.ម. ដែលមានប្រភពដើមមកពីប្រាសាទក្រចាប់ (តំបន់ប្រាសាទកោះកេរ ខេត្តព្រះវិហារ) និងអាចចាត់ថ្នាក់ជាសិល្បៈខ្មែររចនាបថកោះកេរ (គ.ស.៩២១ - ៩៤៥) ពោល គឺស្ថិតនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ ឬព្រះបាទហស៌វរ្ម័នទី២។ សព្វថ្ងៃ គេកំពុងតម្កល់ និងដាក់តាំងបង្ហាញបដិមានេះនៅសារមន្ទីរជាតិកម្ពុជា រាជធានីភ្នំពេញ។ លក្ខណៈសម្គាល់ជាទូទៅរបស់បដិមានេះ គឺមានព្រះកាយម្ខាងខាងស្តាំជាទេពប្រុស (ព្រះឥស្វរ) និងម្ខាងខាងឆ្វេងជាទេពស្រី (ព្រះនាងបវ៌តី ឬឧមា ដែលត្រូវជាព្រះជាយារបស់ព្រះឥស្វរ)។ ការបែងចែករវាងភេទប្រុស និងភេទស្រីនេះ អ្នកឆ្លាក់បានរំលេចតាំងពីព្រះភក្ត្រមកម៉្លេះ ដ្បិតយើងឃើញនៅត្រង់ព្រះគណ្ឌៈ (ថ្ពាល់) នៅចំហៀងខាងឆ្វេង (ខាងស្រី) មានលក្ខណៈប៉ោងធំជាងចំហៀងខាងស្តាំ (ខាងប្រុស)។ រីឯ ចំណុចច្បាស់ជាងគេនោះគឺ ផ្នែកខាងព្រះនាងបវ៌តីពុំមានព្រះមស្សុ (ពុកមាត់) ដូចផ្នែកខាងព្រះឥស្វរឡើយ (ពុកមាត់ងរឡើងទៅលើ)។ ប៉ុន្តែ ចំណុចផ្សេងៗទៀតដូចជា ព្រះនេត្រទីបី ព្រះភមូ (ចិញ្ចើម) មកុដ ផ្នួងសក់ ចំណិតព្រះខៃ មិនមានលក្ខណៈខុសគ្នាអ្វីឡើយ។ ចំណែកនៅត្រង់ផ្នែកព្រះកាយ (ដងខ្លួន) វិញ គេបង្ហាញរូបភាពព្រះថន (សុដន់) ត្រង់ចំហៀងខាងឆ្វេងធំ ជាលក្ខណៈមនុស្សស្រីច្បាស់តែម្តង ហើយនៅខាងក្រោមព្រះថនមានផ្នត់ចំនួន ៤ ថែមទៀតផង ដែលមើលទៅមានលក្ខណៈខុសគ្នាទាំងស្រុងពីផ្នែកខាងស្តាំ។ ក្នុងនោះ ព្រះហស្តខាងស្តាំ (ផ្នែកខាងព្រះឥស្វរ) មានកាន់កេតនភណ្ឌអ្វីមួយដែលយើងមិនច្បាស់ថាជាអ្វីឱ្យប្រាកដឡើយ ដោយសារកេតនភណ្ឌនេះបាក់អស់ផ្នែកខាងលើហើយ ពោលអាចជាត្រីសូល៍ ពូថៅ ស្គរ អង្កប់ (បាស) ឬខ្សែ (អក្ខមាលា)។ រីឯ ព្រះហស្តខាងឆ្វេង (ផ្នែកខាងព្រះនាងបវ៌តី) បានបាក់ត្រង់ប្រអប់ដៃបាត់ទៅហើយ ដូច្នេះគេមិនដឹងថាកាន់អ្វីដូចគ្នា ដែលជាទូទៅច្រើនកាន់ផ្កាឈូក កញ្ចក់ ឬផ្លែឈើ។ អ្វីដែលគួរកត់សម្គាល់បន្ថែមនោះ ព្រះបាទ (ជើង) ទាំងពីរ

អត្ថបទដោយៈ ម៉ង់ រ៉ាលី

*របស់បដិមាមានទំហំមិនដូចគ្នាទេ ពោល គឺផ្នែកខាងស្ដាំ (ព្រះឥសូរ) មានទំហំធំជាងផ្នែកខាងឆ្វេង (ព្រះនាងបវ៌តី) ដែលបង្ហាញឱ្យឃើញភាពជាធម្មជាតិ។ ផ្នែកខាងស្ដាំ (ភេទប្រុស) របស់បដិមាស្លៀកសំពត់ខ្លីចងក្បិន មានជាយធ្លាក់ពីរជាន់ជារាងកន្ទុយត្រី និងផ្នែកខាងឆ្វេង (ភេទស្រី) ស្លៀកសំពត់វែង ដែលសំពត់ទាំងពីរនេះសុទ្ធសឹងមានក្លីច្រើន និងមានជាយធំមួយរាងដូចផ្ចិតធ្លាក់មកចំពីមុខ ដែលគេស្គាល់ជាទូទៅថាសំពត់បដិមារចនាបថកោះកេរ នាស.វ.ទី១០ និងជាលក្ខណៈបន្តវេនពីរចនាបថបាខែង (ខុសគ្នាបន្តិចបន្តួច)។*

*សូមបញ្ជាក់ថា នីតិវិធីនៃការទាមទារយកបដិមានេះត្រឡប់មកវិញ គឺធ្វើឡើងដោយមានកិច្ចសហការជាពិសេសរវាងរាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាសេនាធិការ និងសហរដ្ឋអាមេរិក។ ក្នុងនោះ ការិយាល័យមេធាវីសហរដ្ឋអាមេរិកប្រចាំសង្កាត់ភាគខាងត្បូងនៃទីក្រុងញូវយ៉ក* (SDNY) *និងក្រសួងសន្តិសុខមាតុភូមិអាមេរិក បានស៊ើបអង្កេតរយៈពេល ៣ ឆ្នាំ ហើយបានចោទប្រកាន់លោក* Douglas Latchford *ថា បានជួញដូរវត្ថុសិល្បៈបុរាណខ្មែរដោយខុសច្បាប់។ ជាលទ្ធផលនៅខែកញ្ញា ឆ្នាំ២០២៣ គ្រួសារ* Lindemann *ដែលជាអ្នករក្សាទុកសមុច្ច័យវត្ថុបុរាណខ្មែរ បានស្ម័គ្រចិត្តយល់ព្រមប្រគល់វត្ថុបុរាណចំនួន ៣៣ ដុំ មកកម្ពុជាវិញដោយទទួលស្គាល់ថាវត្ថុបុរាណទាំងនោះ គឺកាន់កាប់ដោយខុសច្បាប់។ ក្រោយមក បដិមាព្រះអធ៌នារីស្វរ និងវត្ថុបុរាណផ្សេងទៀត បានដឹកមកដល់កម្ពុជាវិញនៅខែកក្កដា ឆ្នាំ២០២៤ និងបានធ្វើពិធីទទួលត្រឡប់មកវិញជាផ្លូវការនូវវត្ថុបុរាណខ្មែរចំនួន ៧១ ដុំ នាព្រឹកថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ នៅវិមានសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់* **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** *នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។*

*ជារួមមក ការទាមទារបានមកវិញនូវបដិមាព្រះអធ៌នារីស្វរមកពីប្រាសាទក្រចាប់ នៃតំបន់ប្រាសាទកោះកេរនេះ គឺជាសក្ខីភាពមួយដែលអាចឱ្យគេដឹងថា ការគោរពបូជាព្រហ្មញ្ញសាសនានិកាយសៃវ នៅកម្ពុជាសម័យបុរាណមានលក្ខណៈសម្បូណ៌បែបខ្លាំងណាស់។ ពោល គឺមានការបង្ហាញព្រះឥសូរជាច្រើនរូបភាព បើទោះបីជាព្រះឥសូរក្នុងទម្រង់ជា "អធ៌នារីស្វរ" មិនសូវនិយមធ្លាក់ជាបដិមាដូចទម្រង់ផ្សេងទៀតយ៉ាងណាក៏ដោយ។ បដិមានេះបង្ហាញអំពីគំនិតច្នៃប្រឌិត្ថ និងសមត្ថភាពដ៏ប៉ិនប្រសប់របស់សិល្បករខ្មែរនាសម័យបុរាណ ពាក់ព័ន្ធទៅនឹងសាសនា។*

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*

KHMER CIVILIZATION

## បញ្ជីឯកសារពិគ្រោះ

Blanco, Camille. "Brown's Own Lindemann Family Caught in Cambodian Repatriation Scandal." *Brown Art Review*, 30 October 2023.

Xinhua. "Cambodia celebrates return of 70 looted artifacts from abroad." *Xinhua News Agency*, 22 August 2024.

Woodman, Spencer. "Lindemann family returns 33 long-sought ancient statues to Cambodia." *International Consortium of Investigative Journalists (ICIJ)*, 12 September 2023.

U.S. Attorney's Office, Southern District of New York. "U.S. Attorney Announces Return of Significant Collection of Antiquities to Cambodia." *Department of Justice Press Release*, 12 September 2023.

The Business Times. "Billionaire US collectors to return ancient artefacts to Cambodia." *The Business Times*, 13 September 2023.

Northwest Asian Weekly. "Cambodia's prime minister welcomes artifacts returned by New York's Met and other collections." *Northwest Asian Weekly*, 23 August 2024.

**Boisselier, Jean**. *La Statuaire Khmère et son Évolution*. Saigon: École Française d'Extrême-Orient, 1966.

**Doniger O'Flaherty**, Wendy. *Siva: The Erotic Ascetic*. New York: Oxford University Press, 1973.

**Flood, Gavin**. *An Introduction to Hinduism*. Cambridge: Cambridge University Press, 1996.

**Zimmer, Heinrich**. *Myths and Symbols in Indian Art and Civilization*. Edited by Joseph Campbell. Princeton: Princeton University Press, 1972.

អរិយធម៌ខ្មែរ
KHMER CIVILIZATION




រូបលេខ១-២៖ បដិមាព្រះអធំនារីស្វរមកពីប្រាសាទក្រចាប់ តំបន់កោះកេរ (សារមន្ទីរជាតិកម្ពុជា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ៧-៨៖ បដិមាព្រះអធំនារីស្វរមកពីប្រាសាទក្រចាប់ តំបន់កោះកេរ (សារមន្ទីរជាតិកម្ពុជា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ៥-៦៖ លម្អិតកិនភាគបដិមាព្រះអធំនារីស្វរមកពីប្រាសាទក្រចាប់

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី